ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

ថ្ងៃអង្គារ ១៥កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

## ការកែសម្រួលលក្ខខណ្ឌធ្វើដំណើររបស់ជនបរទេស មកកាន់ប្រទេសកម្ពុជា

ក្នុងវត្ថុបំណងផ្តល់ភាពងាយស្រួលដល់អ្នកដំណើរបរទេស ដែលបានមកដល់ ឬ គ្រោងធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ក្រសួងសុខាភិបាលមានកិត្តិយសជម្រាបជូនដំណឹងថា រាជរដ្ឋាភិបាលកម្ពុជានឹងអនុវត្តយន្តការធានា ( Sponsorship Mechanism ) ដើម្បីជួយសម្រួលអ្នកធ្វើដំណើរបរទេស ដែលជាវិនិយោគិន-ធុរជន បុគ្គលិកក្រុមហ៊ុន អ្នកជំនាញការ កម្មករជំនាញ អ្នកបច្ចេកទេស និងក្រុមគ្រួសារ ដែលមានការធានា ឬ មានការអញ្ជើញតែមិនមានការធានា ឬ មិនមានការអញ្ជើញ និងមិនមានការធានា ឬ អ្នកធ្វើដំណើរបរទេសទូទៅ ដូចខាងក្រោម៖

**១. ចំពោះអ្នកធ្វើដំណើរបរទេសដែលជាវិនិយោគិន-ធុរជន បុគ្គលិកក្រុមហ៊ុន អ្នកជំនាញការ កម្មករជំនាញ អ្នកបច្ចេកទេស និងក្រុមគ្រួសារ ដែលទទួលបានការធានា**

**ក. មុនពេលធ្វើដំណើរមកដល់ប្រទេសកម្ពុជា៖**

អ្នកធ្វើដំណើរបរទេស ត្រូវមានឯកសារ ដូចខាងក្រោម៖

- វិញ្ញាបនបត្របញ្ជាក់សុខភាព ចេញដោយអាជ្ញាធរសុខាភិបាល ដែលទទួលស្គាល់ដោយរដ្ឋាភិបាលប្រទេសសាមី បញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ម៉ោង មុនពេលចេញដំណើរ។
- លិខិតបញ្ជាក់លើការធានាទូទាត់សងប្រាក់ ដែលចេញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីទទួលបានលិខិតនេះ អ្នកធ្វើដំណើរបរទេសត្រូវមានការធានា ពីបុគ្គលដែលមានសិទ្ធិផ្តល់ការធានា ដែលក្នុងនោះរួមមាន នាយកប្រតិបត្តិ ឬ ម្ចាស់ភាគហ៊ុននៃក្រុមហ៊ុន ដែលកំពុងមានធុរកិច្ច និងអាសយដ្ឋានច្បាស់លាស់នៅកម្ពុជា។ ភាគីអ្នកធានាត្រូវបំពេញពាក្យស្នើសុំការធានាតាមអនឡាញនៅក្នុង:
    - គេហទំព័រចុះបញ្ជីអាជីវកម្មរបស់រាជរដ្ឋាភិបាល( www.registrationservices.gov.kh ) ឬ



ទីស្តីការក្រសួងសុខាភិបាល មហាវិថីលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៤ ៩១០ / ៨៨៤ ៩០៥

○ នៅក្នុងតំណភ្ជាប់ដែលមាននៅក្នុងគេហទំព័ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (www.cdc.gov.kh) ឬ

○ គេហទំព័ររបស់ក្រសួងសុខាភិបាល (www.cdcmoh.gov.kh) ។

ការធានានឹងត្រូវការរយៈពេល ០១ (មួយ) ថ្ងៃ ដើម្បីពិនិត្យ និងវាយតម្លៃដោយស្ថាប័នមានសមត្ថកិច្ច។ ក្នុងករណីដែលពិនិត្យឃើញថា ការធានានេះមានភាពត្រឹមត្រូវ រាជរដ្ឋាភិបាលនឹងចេញលិខិតបញ្ជាក់លើការធានាទូទាត់សងប្រាក់ ដែលអ្នកធ្វើដំណើរបរទេសអាចបោះពុម្ពបានសម្រាប់កាន់ភ្ជាប់មកជាមួយក្នុងការដាក់ពាក្យស្នើសុំទិដ្ឋាការ នៅស្ថានទូតកម្ពុជា ឬ ស្ថានកុងស៊ុលកម្ពុជា និងក្នុងការធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ។

- ទិដ្ឋាការដែលមានសុពលភាពស្របតាមនីតិវិធី នៃច្បាប់ស្តីពីអន្តោប្រវេសន៍ ដែលត្រូវបានផ្តល់ឱ្យពីសំណាក់ស្ថានទូតកម្ពុជា ឬ ពីស្ថានកុងស៊ុលកម្ពុជា នៃប្រទេសសាមី ។
- លិខិត ឬ ឯកសារបញ្ជាក់ពីការបានកក់បន្ទប់សណ្ឋាគារ (Proof of Online Booking) សម្រាប់ការស្នាក់នៅ ដែលការកក់បន្ទប់សណ្ឋាគារនេះ ត្រូវធ្វើឱ្យបានយ៉ាងតិច ០៣ (បី) ថ្ងៃ មុនពេលចេញដំណើរ។ ចំណាយទៅលើការកក់បន្ទប់សណ្ឋាគារនេះ គឺជាចំណាយសរុបដែលរួមមានថ្លៃស្នាក់នៅសណ្ឋាគារសម្រាប់រយៈពេល ០២ (ពីរ)យប់ ថ្លៃអាហាររយៈពេល ០២ (ពីរ)ថ្ងៃ ថ្លៃធ្វើតេស្តរកមេរោគកូវីដ-១៩ លើកទី១ និងថ្លៃដឹកជញ្ជូនពីអាកាសយានដ្ឋានអន្តរជាតិទៅសណ្ឋាគារ។ (បញ្ជាក់៖ អ្នកដំណើរបរទេសអាចតម្រូវឱ្យស្នាក់នៅក្នុងសណ្ឋាគារដែលបានកក់ រហូតដល់រយៈពេល ០២ (ពីរ)យប់ ក្នុងករណីដែលលទ្ធផល នៃការធ្វើតេស្តរកមេរោគកូវីដ-១៩ លើកទី១ មិនទាន់ចេញលទ្ធផល)

ចំពោះចំណាយសរុប និងជម្រើសសណ្ឋាគារដែលអាចកក់បានរួមមាន ដូចតទៅ៖

○ សណ្ឋាគារ សុខាភ្នំពេញ ដែលមានថ្លៃចំណាយសរុបចំនួន ៣៨៥ដុល្លារអាមេរិក (ចំនួន ២២០ដុល្លារអាមេរិក សម្រាប់ថ្លៃសណ្ឋាគារ ៦០ដុល្លារអាមេរិក សម្រាប់ថ្លៃអាហារ ១០៥ដុល្លារអាមេរិក សម្រាប់ថ្លៃធ្វើតេស្តរកមេរោគកូវីដ-១៩ លើកទី១ និងថ្លៃដឹកជញ្ជូនពីអាកាសយានដ្ឋានអន្តរជាតិទៅសណ្ឋាគារ)។

អាសយដ្ឋាន៖ វិថីកែវចិន្តា សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

គេហទំព័រ www.sokhahotels.com

ទូរស័ព្ទលេខៈ (+៨៥៥) (០)២៣ ៦៨៥ ៨៨៨៨

- សណ្ឋាគារអន្តរជាតិ ធៀន យី ដែលមានថ្លៃចំណាយសរុប ៣១៥ដុល្លារអាមេរិក (១៥០ដុល្លារអាមេរិក សម្រាប់ថ្លៃសណ្ឋាគារ ៦០ដុល្លារអាមេរិក សម្រាប់ថ្លៃអាហារ ១០៥ដុល្លារអាមេរិក សម្រាប់ថ្លៃធ្វើតេស្តរកមេរោគកូវីដ-១៩ លើកទី១ និងថ្លៃដឹកជញ្ជូនពីអាកាសយានដ្ឋានអន្តរជាតិទៅសណ្ឋាគារ) ។

  អាសយដ្ឋាន៖ អគារលេខ១១២ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

  គេហទំព័រ www.tianyihotels.com,

  ទូរស័ព្ទលេខ: (+៨៥៥) (០)៨៩ ៣៣៨ ២៣៣៣

ក្នុងករណីមានថវិកានៅសេសសល់ក្រោយពីការទូទាត់ចំណាយជាក់ស្តែង សណ្ឋាគារនឹងបង្វែរប្រាក់ដែលនៅសល់នោះ ជូនទៅអ្នកដំណើរបរទេសវិញ ។

ខ. ពេលមកដល់អាកាសយានដ្ឋានអន្តរជាតិនៃប្រទេសកម្ពុជា៖

ខ.១: អ្នកធ្វើដំណើរបរទេស ត្រូវ៖

- បង្ហាញទិដ្ឋាការដែលមានសុពលភាព និងចេញដោយស្ថានទូតកម្ពុជា ឬ ពីស្ថានកុងស៊ុលកម្ពុជានៃប្រទេសសាមីវិញ្ញាបនបត្របញ្ជាក់សុខភាពចេញដោយ អាជ្ញាធរសុខាភិបាលដែលទទួលស្គាល់ដោយរដ្ឋាភិបាលប្រទេសសាមី បញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ម៉ោង មុនពេលចេញដំណើរ លិខិតបញ្ជាក់លើការធានាទូទាត់សងប្រាក់ និងលិខិត ឬ ឯកសារបញ្ជាក់ពីការបានកក់បន្ទប់សណ្ឋាគារ ( Proof of Online Booking )។
- បន្ទាប់ពីទទួលបានការត្រួតពិនិត្យឯកសារតម្រូវដូចខាងលើ អ្នកដំណើរបរទេសនឹងមានសិទ្ធិប្រើប្រាស់ផ្លូវអាទិភាពពិសេស ដើម្បីទទួលបានការពិនិត្យសុខភាព និងការយកសំណាកដែលនឹងអនុវត្តដោយមន្ត្រីសុខាភិបាល មុននឹងត្រូវដឹកជញ្ជូនទៅសណ្ឋាគារ ដែលអ្នកដំណើរបរទេសបានកក់ទុក ។

ខ.២: ក្នុងករណីដែលអ្នកធ្វើដំណើរបរទេស តម្រូវឱ្យធ្វើចត្តាឡីស័កសម្រាប់រយៈពេល ១៤ថ្ងៃ អ្នកធានាត្រូវទទួលរ៉ាប់រងលើរាល់ចំណាយទាំងស្រុង ដោយតម្រូវឱ្យ៖

- បង់ប្រាក់ចំណាយទៅតាមវិក្កយបត្រជាក់ស្តែង ចំពោះការស្នាក់នៅសម្រាប់រយៈពេល ១៤ (ដប់បួន)ថ្ងៃ របស់អ្នកធ្វើដំណើរបរទេសឱ្យបានមុនថ្ងៃទី០៧ (ប្រាំពីរ)ថ្ងៃ នៃការស្នាក់នៅ។
- ទូទាត់ថ្លៃធ្វើតេស្តរកមេរោគកូវីដ-១៩ លើកបន្ទាប់ ជូនក្រសួងសុខាភិបាល នៅពេលបញ្ចប់ការធ្វើចត្តាឡីស័កសម្រាប់រយៈពេល ១៤ ថ្ងៃនេះ ។

១.៣: ក្នុងករណីដែលអ្នកធ្វើដំណើរបរទេសមានជំងឺកូវីដ-១៩ ក្នុងអំឡុងពេលស្នាក់នៅក្នុងប្រទេសកម្ពុជា អ្នកធានាត្រូវតែទទួលរ៉ាប់រងលើរាល់ចំណាយសម្រាប់ការព្យាបាលអ្នកជំងឺ រហូតដល់ជាសះស្បើយ និងត្រូវទូទាត់ជូនមន្ទីរពេទ្យរដ្ឋ ដែលអ្នកជំងឺកូវីដ-១៩ បានសម្រាកព្យាបាល។

១.៤: ភាគីអ្នកធានាត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងផ្ដល់កិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយក្រសួងសុខាភិបាល ក្នុងការសម្រួលការធ្វើដំណើររបស់អ្នកធ្វើដំណើរបរទេស ដែលត្រូវបានធានា។

**២. ចំពោះអ្នកធ្វើដំណើរបរទេស ដែលជាវិនិយោគិន-ធុរជន បុគ្គលិកក្រុមហ៊ុន អ្នកជំនាញការ កម្មករជំនាញ អ្នកបច្ចេកទេស និងក្រុមគ្រួសារ ដែលមិនមានការធានា ប៉ុន្តែទទួលបានការអញ្ជើញ៖**

**ក. មុនពេលធ្វើដំណើរមកដល់ប្រទេសកម្ពុជា៖**

អ្នកធ្វើដំណើរបរទេស ត្រូវមានឯកសារដូចខាងក្រោម៖

- វិញ្ញាបនបត្របញ្ជាក់សុខភាពចេញដោយអាជ្ញាធរសុខាភិបាល ដែលទទួលស្គាល់ដោយរដ្ឋាភិបាលប្រទេសសាមី បញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ម៉ោង មុនពេលចេញដំណើរ។
- លិខិតបញ្ជាក់លើការអញ្ជើញ ដែលចេញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីទទួលបានលិខិតនេះ អ្នកធ្វើដំណើរបរទេសត្រូវមានការអញ្ជើញ ពីបុគ្គលដែលមានសិទ្ធិផ្តល់ការអញ្ជើញ ដែលក្នុងនោះរួមមាន នាយកប្រតិបត្តិ ឬ ម្ចាស់ភាគហ៊ុន នៃក្រុមហ៊ុន ដែលកំពុងមានធុរកិច្ច និងអាសយដ្ឋានច្បាស់លាស់នៅកម្ពុជា។ ភាគីអញ្ជើញ ត្រូវបំពេញពាក្យស្នើសុំការអញ្ជើញតាមអនឡាញ នៅក្នុង:
  - គេហទំព័រចុះបញ្ជីអាជីវកម្មរបស់រាជរដ្ឋាភិបាល(www.registrationservices.gov.kh) ឬ
  - នៅក្នុងតំណភ្ជាប់ដែលមាននៅក្នុងគេហទំព័ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (www.cdc.gov.kh) ឬ
  - គេហទំព័ររបស់ក្រសួងសុខាភិបាល (www.cdcmoh.gov.kh) ។

បន្ទាប់ពីបានពិនិត្យលើភាពត្រឹមត្រូវរបស់ការអញ្ជើញនេះ ដែលនឹងត្រូវការរយៈពេល ០១ (មួយ)ថ្ងៃ រាជរដ្ឋាភិបាលនឹងចេញលិខិតបញ្ជាក់លើការអញ្ជើញ ដែលអ្នកដំណើរបរទេសអាចបោះពុម្ពបានសម្រាប់កាន់ភ្ជាប់មកជាមួយក្នុងការដាក់ពាក្យស្នើសុំទិដ្ឋាការ នៅស្ថានទូតកម្ពុជា ឬ ស្ថានកុងស៊ុលកម្ពុជា និងក្នុងការធ្វើដំណើរមកកាន់ប្រទេសកម្ពុជា។

- ទិដ្ឋាការដែលមានសុពលភាពស្របតាមនីតិវិធី នៃច្បាប់ស្តីពីអន្តោប្រវេសន៍ ដែលត្រូវបានផ្តល់ឱ្យពីសំណាក់ស្ថានទូតកម្ពុជា ឬ ពីស្ថានកុងស៊ុលកម្ពុជា នៃប្រទេសសាមី ។
- លិខិតបញ្ជាក់លើការទិញសេវាធានារ៉ាប់រងសុខភាព ដែលតម្រូវឱ្យអ្នកធ្វើដំណើរបរទេសទិញសេវាធានារ៉ាប់រងសុខភាព (Health Insurance) សម្រាប់ព្យាបាលជំងឺកូវីដ-១៩ ក្នុងតម្លៃ ៩០

(កៅសិប) ដុល្លារអាមេរិក និងមានរយៈពេលធានា ២០ (ម្ភៃ) ថ្ងៃ។ កញ្ចប់ធានានេះអាចទិញបាន ពីក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ (FORTE Insurance) តាមរយៈគេហទំព័រ: https://www.forteinsurance.com/covid-19-insurance/

- លិខិត ឬ ឯកសារបញ្ជាក់ពីការបានកក់បន្ទប់សណ្ឋាគារ (Proof of Online Booking) សម្រាប់ការស្នាក់នៅ ដែលការកក់បន្ទប់សណ្ឋាគារនេះ ត្រូវធ្វើឱ្យបានយ៉ាងតិច ០៣ (បី)ថ្ងៃ មុនពេលចេញដំណើរ។ ចំណាយទៅលើការកក់បន្ទប់សណ្ឋាគារនេះ គឺជាចំណាយសរុបដែលរួមមានថ្លៃស្នាក់នៅសណ្ឋាគារសម្រាប់រយៈពេល ០២ (ពីរ)យប់ ថ្លៃអាហាររយៈពេល ០២ (ពីរ)ថ្ងៃ ថ្លៃធ្វើតេស្តរកមេរោគកូវីដ-១៩ លើកទី១ និងថ្លៃដឹកជញ្ជូនពីអាកាសយានដ្ឋានអន្តរជាតិទៅសណ្ឋាគារ ។ (បញ្ជាក់៖ អ្នកដំណើរបរទេសអាចតម្រូវឱ្យស្នាក់នៅក្នុងសណ្ឋាគារដែលបានកក់ ហួសដល់រយៈពេល ០២(ពីរ)យប់ ក្នុងករណីដែលលទ្ធផលនៃការធ្វើតេស្តរកមេរោគកូវីដ-១៩ លើកទី១ មិនទាន់ចេញលទ្ធផល)

  ចំពោះចំណាយសរុប និងជម្រើសសណ្ឋាគារដែលអាចកក់បានរួមមាន ដូចតទៅ៖

  - **សណ្ឋាគារ សុខាភ្នំពេញ** ដែលមានថ្លៃចំណាយសរុបចំនួន ៣៨៥ដុល្លារអាមេរិក (ចំនួន ២២០ដុល្លារអាមេរិក សម្រាប់ថ្លៃសណ្ឋាគារ ៦០ដុល្លារអាមេរិក សម្រាប់ថ្លៃអាហារ ១០៥ ដុល្លារអាមេរិក សម្រាប់ថ្លៃធ្វើតេស្តរកមេរោគកូវីដ-១៩ លើកទី១ និងថ្លៃដឹកជញ្ជូនពីអាកាសយានដ្ឋានអន្តរជាតិទៅសណ្ឋាគារ)។

    អាសយដ្ឋាន៖ វិថីកែវចិន្តា សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
    គេហទំព័រ www.sokhahotels.com,
    ទូរស័ព្ទលេខ: (+៨៥៥) (០)២៣ ៦៨៥ ៨៨៨៨

  - **សណ្ឋាគារអន្តរជាតិ ធៀន យី** ដែលមានថ្លៃចំណាយសរុប ៣១៥ដុល្លារអាមេរិក (១៥០ ដុល្លារអាមេរិក សម្រាប់ថ្លៃសណ្ឋាគារ ៦០ដុល្លារអាមេរិក សម្រាប់ថ្លៃអាហារ ១០៥ដុល្លារអាមេរិក សម្រាប់ថ្លៃធ្វើតេស្តរកមេរោគកូវីដ-១៩ លើកទី១ និងថ្លៃដឹកជញ្ជូនពីអាកាសយានដ្ឋានអន្តរជាតិទៅសណ្ឋាគារ)។

    អាសយដ្ឋាន៖ អគារលេខ១១២ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
    គេហទំព័រ www.tianyihotels.com,
    ទូរស័ព្ទលេខ: (៨៥៥) (០)៨៨ ៣៣៨ ២៣៣៣

ក្នុងករណីមានថវិកានៅសេសសល់ក្រោយពីការទូទាត់ចំណាយជាក់ស្តែង សណ្ឋាគារនឹងបង្វែរប្រាក់ដែលនៅសល់នោះ ជូនទៅអ្នកដំណើរបរទេសវិញ ។

**២. ពេលមកដល់អាកាសយានដ្ឋានអន្តរជាតិនៃប្រទេសកម្ពុជា៖**

អ្នកធ្វើដំណើរបរទេស ត្រូវ៖

- បង្ហាញទិដ្ឋាការដែលមានសុពលភាព និងចេញដោយស្ថានទូតកម្ពុជា ឬ ពីស្ថានកុងស៊ុលកម្ពុជានៃប្រទេសសាមី វិញ្ញាបនបត្របញ្ជាក់សុខភាពចេញដោយអាជ្ញាធរសុខាភិបាល ដែលទទួលស្គាល់ដោយរដ្ឋាភិបាលប្រទេសសាមី បញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ម៉ោង មុនពេលចេញដំណើរ លិខិតបញ្ជាក់លើការអញ្ជើញ លិខិតបញ្ជាក់លើការទិញសេវាធានារ៉ាប់រងសុខភាព និងលិខិត ឬ ឯកសារបញ្ជាក់ពីការបានកក់បន្ទប់សណ្ឋាគារ ( Proof of Online Booking )។
- ដាក់ប្រាក់តម្កល់ចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក សម្រាប់ចំណាយលើថ្លៃស្នាក់នៅក្នុងអំឡុងពេលរង់ចាំលទ្ធផលធ្វើតេស្តរកមេរោគកូវីដ-១៩ ថ្លៃធ្វើតេស្ត ថ្លៃដឹកជញ្ជូនពីអាកាសយានដ្ឋានអន្តរជាតិទៅសណ្ឋាគារដែលបានកក់ និងចំណាយអំឡុងពេលធ្វើចត្តាឡីស័ក ក្នុងករណីដែលអ្នករួមដំណើរណាម្នាក់មានវិជ្ជមានជំងឺកូវីដ-១៩។
- បន្ទាប់ពីទទួលបានការត្រួតពិនិត្យឯកសារ និងបំពេញលក្ខខណ្ឌតម្រូវដូចខាងលើ អ្នកធ្វើដំណើរបរទេសនឹងមានសិទ្ធិប្រើប្រាស់ផ្លូវអាទិភាពពិសេស ដើម្បីទទួលបានការពិនិត្យសុខភាព និងការយកសំណាកដែលនឹងអនុវត្តដោយមន្ត្រីសុខាភិបាល មុននឹងត្រូវដឹកជញ្ជូនទៅសណ្ឋាគារ ដែលអ្នកធ្វើដំណើរបរទេសបានកក់ទុក ។

**៣. ចំពោះអ្នកធ្វើដំណើរបរទេស ដែលជាវិនិយោគិន-ធុរជន បុគ្គលិកក្រុមហ៊ុន អ្នកជំនាញការ កម្មករជំនាញ អ្នកបច្ចេកទេស និងក្រុមគ្រួសារ ដែលមិនមានការធានា និងមិនទទួលបានការអញ្ជើញ៖**

កម្ពុជាសូមស្វាគមន៍ចំពោះការធ្វើដំណើរមកដល់របស់អ្នកធ្វើដំណើរបរទេស ដែលជាវិនិយោគិន-ធុរជន បុគ្គលិកក្រុមហ៊ុន អ្នកជំនាញការ កម្មករជំនាញ អ្នកបច្ចេកទេស និងក្រុមគ្រួសារ ដែលមិនមានការធានា និងមិនទទួលបានការអញ្ជើញ។ អ្នកធ្វើដំណើរបរទេសទាំងនេះ នឹងត្រូវអនុវត្តដូចអ្នកធ្វើដំណើរបរទេសទូទៅដទៃទៀត ដែលមានចែងក្នុងចំណុចទី ៤ ខាងក្រោម ។

**៤. អ្នកធ្វើដំណើរបរទេសទូទៅដទៃទៀត ដែលគ្រោងនឹងធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ត្រូវ៖**

ក- អនុវត្តតាមសេចក្តីជូនដំណឹងលេខ ៥៦៤ សនថហ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល ស្តីពីការគិតថ្លៃសេវាធ្វើតេស្តរកមេរោគកូវីដ-១៩ ការធ្វើចត្តាឡីស័ក និងការពិនិត្យព្យាបាលជំងឺកូវីដ-១៩ នៅមន្ទីរពេទ្យរដ្ឋ ដែលនៅអនុវត្តជាធរមាន ។

ខ- ដាក់ប្រាក់តម្កល់ចំនួន ២.០០០ ( ពីរពាន់ )ដុល្លារអាមេរិក នៅពេលមកដល់អាកាសយានដ្ឋានអន្តរជាតិនៃប្រទេសកម្ពុជា ដែលប្រាក់នេះនឹងត្រូវប្រើសម្រាប់ចំណាយលើថ្លៃស្នាក់នៅក្នុងអំឡុងពេលរង់ចាំលទ្ធផលធ្វើតេស្តរកមេរោគកូវីដ-១៩ ថ្លៃធ្វើតេស្ត ថ្លៃដឹកជញ្ជូនពីអាកាសយានដ្ឋានអន្តរជាតិទៅសណ្ឋាគារ ដែលបានកក់ និងចំណាយអំឡុងពេលធ្វើចត្តាឡីស័ក ( ក្នុងករណីដែលអ្នករួមដំណើរណាម្នាក់មានវិជ្ជមានជំងឺកូវីដ-១៩ )។

គ- ទិញសេវាធានារ៉ាប់រងសុខភាព ( Health Insurance ) សម្រាប់ព្យាបាលជំងឺកូវីដ-១៩ ក្នុងតម្លៃ ៩០ ( កៅសិប ) ដុល្លារអាមេរិក និងមានរយៈពេលធានា ២០ ( ម្ភៃ ) ថ្ងៃ ។ កញ្ចប់ធានានេះអាចទិញបានពីក្រុមហ៊ុនធានារ៉ាប់រងហ្វតេ (FORTE Insurance) តាមរយៈគេហទំព័រ https://www.forteinsurance.com/covid-19-insurance/

**៥. គ្រប់អ្នកធ្វើដំណើរដូចមានក្នុងចំណុចទី១ ទី២ ទី៣ និងទី៤ ដែលបានចូលមកប្រទេសកម្ពុជា ត្រូវមកធ្វើតេស្តរកមេរោគកូវីដ-១៩ បន្តបន្ទាប់ ដោយអនុលោមតាមវិធានសុខាភិបាល នៅមូលដ្ឋានសុខាភិបាលសាធារណៈ។**

សេចក្តីដូចបានជម្រាបជូនខាងលើ សូមអ្នកធ្វើដំណើរបរទេស ដែលជាវិនិយោគិន-ធុរជន បុគ្គលិកក្រុមហ៊ុន អ្នកជំនាញការ កម្មករជំនាញ អ្នកបច្ចេកទេស ក្រុមគ្រួសារ និងអ្នកដំណើរបរទេសទូទៅ មេត្តាជ្រាប និងចូលរួមសហការប្រកបដោយការទទួលខុសត្រូវ ដើម្បីរួមគ្នាអនុវត្តវិធានការប្រយុទ្ធនឹងជំងឺកូវីដ-១៩ របស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃប្រកាសផ្សព្វផ្សាយសេចក្តីជូនដំណឹងនេះជាសាធារណៈ។